# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការទាត់ថ្នាក់ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការធ្វើអនុបយោគ និង ការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ នៅឃុំខ្នារសណ្ដាយ និង ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងបទបញ្ជា ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ .-**

ត្រូវបានចាត់ថ្នាក់ជាព្រៃការពារ សិក្សាស្រាវជ្រាវ នូវព្រៃបម្រុងទុកអចិន្ត្រៃយ៍ទំហំ ប្រាំពីររយម្ភៃប្រាំពីរហិកតា (៧២៧ហ.ត) ស្ថិតនៅឃុំខ្នារសណ្តាយ និង ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមាននិយាមកា : G:391360, 1511452 H:390736, 1511413 I:390334, 1511387 J:389772, 1511382 K:387278, 1511248 L:384660, 1510929 M:384655, 1510912 N:384627, 1510893 W: 390430, 1508979 X:390012, 1509119 ។

**មាត្រា ២ .-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវព្រៃបម្រុងទុកអចិន្ត្រៃយ៍ ទំហំពីរពាន់ប្រាំរយប្រាំពីរហិកតា (២.៥០៧ ហ.ត )ស្ថិតនៅឃុំខ្នារសណ្តាយ និង ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមាននិយាមកា : A:386704, 1513167 B:386171, 1511900 C:387281, 1511557 D:388111, 1512001 E:390974, 1512165 F:391615, 1512198 G: 391360, 1511452 H: 390736, 1511413 I: 390334, 1511387 J: 389772, 1511382 K: 387278, 1511248 L: 384660, 1510929 M:384655, 1510912 N:384627, 1510893 W: 390430, 1508979 X:390012, 1509119 Q:389681, 1506817 R:384282, 1507182 S:384424, 1507453 T: 383906, 1507504 U: 383559, 1509497 V:384479, 1512410 ។

**មាត្រា ៣ .-**

ត្រូវបានផ្ទេរផ្ទៃដីព្រៃ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ទំហំពីរពាន់ប្រាំរយប្រាំពីរហិកតា (២.៥០៧ ហ.ត)ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

**មាត្រា ៤ .-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំពីរពាន់ប្រាំរយប្រាំពីរហិកតា (២.៥០៧ ហ.ត )ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ៚

**មាត្រា ៥ .-**

ផ្ទៃដីទំហំពីរពាន់ប្រាំរយប្រាំពីរហិកតា (២.៥០៧ ហ.ត ) ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋដូចតទៅ :

- ជូនអាជ្ញាធរកាន់កាប់ដីរដ្ឋខេត្តសៀមរាប ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច តាមនីតិវិធីច្បាប់ជាធរមាន ទំហំមួយពាន់បីរយដប់ប្រាំពីរហិកតា( ១.៣១៧ ហ.ត)ដែលមាននិយាមកា : A:386704, 1513167 B: 386171, 1511900 C:387281, 1511557 D:388111, 1512001E:390974, 1512165 F:391615, 1512198 G:391360, 1511452 H:390736, 1511413 I:390334, 1511387 J:389772, 1511382 K:387278, 1511248 L:384660, 1510929 M:384655, 1510912 N:384627, 1510893 O:384598, 1509497 P:384603, 1508776 Q:389681, 1506817 R:384282, 1507182 S: 384424, 1507453 T:383906, 1507504 U:383559, 1509497 V:384479, 1512410 ។
- ជូនអាជ្ញាធរកាន់កាប់ដីរដ្ឋក្រសួងការពារជាតិ ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រគល់សិទ្ធិប្រើប្រាស់ រក្សាការពារ និង បែងចែកជូនគ្រួសារយុទ្ធជនតាមការជាក់ស្តែង ដោយកងពលតូចអន្តរាគមន៍លេខ ៤ ចំណុះឱ្យកងពលធំអន្តរាគមន៍លេខ ២ ទំហំមួយពាន់មួយរយហាសិបហិកតា (១.១៥០ ហ.ត) ដែលមាននិយាមកា: N:384627, 1510893 W:390430, 1508979 X:390012, 1509119 Q:389681, 1506817 P:384603, 1508776 O:384598, 1509497 ។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ